សេចក្ដីសង្ខេបព័ត៌មាន និងព្រឹត្តិការណ៍សំខាន់ៗប្រចាំខែកញ្ញា របស់និយ័តករគណនេយ្យ និងសវនកម្ម នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ រួមមានដូចខាងក្រោម៖

## ព័ត៌មានថ្មីៗ


កិច្ចប្រជុំគណៈកម្មាធិការកែទម្រង់ សូមអាននៅទំព័រ....១
កិច្ចប្រជុំគណៈកម្មាធិការកែទម្រង់ សូមអាននៅទំព័រ...២
កិច្ចប្រជុំពិភាក្សាពីការទទួលស្គាល់របាយការណ៍ហិរញ្ញវត្ថុ សូមអាននៅទំព័រ..........................................២
កិច្ចប្រជុំកម្រិតថ្នាក់ដឹកនាំ សូមអាននៅទំព័រ..........៣
កិច្ចប្រជុំលើកទី៣ សូមអាននៅទំព័រ......................៣
កិច្ចប្រជុំដើម្បីពិនិត្យ សូមអាននៅទំព័រ....................៤
សិក្ខាសាលា សូមអាននៅទំព័រ...............................៥
សិក្ខាសាលាផ្សព្វផ្សាយ សូមអាននៅទំព័រ.............៥
កិច្ចប្រជុំពិភាក្សា សូមអាននៅទំព័រ.........................៦
សិក្ខាសាលា សូមអាននៅទំព័រ...............................៧
កម្មវិធីប្រគល់វិញ្ញាបនបត្រ សូមអាននៅទំព័រ..............៧
វគ្គបណ្តុះបណ្តាល សូមអាននៅទំព័រ.......................៨
វគ្គបណ្តុះបណ្តាល សូមអាននៅទំព័រ.......................៩
សិក្ខាសាលា សូមអាននៅទំព័រ...............................៩
កិច្ចប្រជុំ និងពិភាក្សា សូមអាននៅទំព័រ...................១០
កម្មវិធីចុះហត្ថលេខា សូមអាននៅទំព័រ..................១០
កិច្ចប្រជុំពិនិត្យនិងពិភាក្សា សូមអាននៅទំព័រ.........១១
កម្មវិធីចុះអនុស្សរណៈ សូមអាននៅទំព័រ...............១១
កិច្ចប្រជុំពិគ្រោះយោបល់ សូមអាននៅទំព័រ...........១១
សន្និសីទ សូមអាននៅទំព័រ..................................១២


## កិច្ចប្រជុំគណៈកម្មាធិការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដើម្បីពិនិត្យ និងពិភាក្សាលើរបាយការណ៍សមិទ្ធកម្មប្រចាំត្រីមាសទី២ ឆ្នាំ២០២៤



១.កាលពីថ្ងៃពុធ ៩ កើត ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី ១១ ខែកញ្ញា គ.ស. ២០២៤ **ឯកឧត្តម ម៉ី ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយ **លោកស្រី នាន បូនី** អគ្គនាយករង, **លោក ទឹម សត្យា** អនុប្រធាននាយកដ្ឋានទទួលបន្ទុករួម នាយកដ្ឋានកិច្ចការទូទៅ និង**លោកស្រី ហា សុគន្ធា** ប្រធានការិយាល័យគណនេយ្យនិងហិរញ្ញវត្ថុ បានចូលរួមកិច្ចប្រជុំគណៈកម្មាធិការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដើម្បីពិនិត្យនិងពិភាក្សាលើរបាយការណ៍សមិទ្ធកម្មប្រចាំត្រីមាសទី២ គ.ស. ២០២៤តាមរយៈប្រព័ន្ធអនឡាញ ដែលដឹកនាំដោយ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រង ការងារហិរញ្ញវត្ថុសាធារណៈ**។

## កិច្ចប្រជុំគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីពិនិត្យ និងពិភាក្សាលើរបាយការណ៍សមិទ្ធកម្មប្រចាំត្រីមាសទី២ ឆ្នាំ២០២៤



© រក្សាសិទ្ធិដោយ និយ័តករគណនេយ្យនិងសវនកម្ម

២.កាលពីថ្ងៃចន្ទ ១៤ កើត ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី១៦ ខែកញ្ញា គ.ស. ២០២៤ **លោកស្រី នាន បូនី** អគ្គនាយករង តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ម៉ី ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយដោយ **លោក ទឹម សត្យា** អនុប្រធាននាយកដ្ឋានទទួលបន្ទុកនៃរួមនាយកដ្ឋានកិច្ចការទូទៅនិង **លោកស្រី ហា សុគន្ធា** ប្រធានការិយាល័យគណនេយ្យនិងហិរញ្ញវត្ថុ បានចូលរួមកិច្ចប្រជុំ គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីពិនិត្យនិងពិភាក្សាលើរបាយការណ៍សមិទ្ធកម្មប្រចាំត្រីមាសទី២ គ.ស. ២០២៤ តាមរយៈប្រព័ន្ធអនឡាញ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ ការគ្រប់គ្រងការងារហិរញ្ញវត្ថុសាធារណៈ**។

## កិច្ចប្រជុំពិភាក្សាស្តីពីការទទួលស្គាល់របាយការណ៍ហិរញ្ញវត្ថុដែលធ្វើសវនកម្មដោយសវនករឯករាជ្យរបស់ក្រុមហ៊ុនបោះផ្សាយដោយអគ្គនាយកដ្ឋានពន្ធដារ



៣.កាលពីថ្ងៃច័ន្ទ ១៤រោច ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី២ ខែកញ្ញា គ.ស. ២០២៤ នៅសាលប្រជុំធំ អគារ "គ" នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ **ឯកឧត្តម ម៉ី ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយ **លោកស្រី នាន បូនី** អគ្គនាយករង ព្រមទាំងមន្ត្រីបច្ចេកទេស បានចូលរួមកិច្ចប្រជុំពិភាក្សាស្តីពីការទទួលស្គាល់របាយការណ៍ហិរញ្ញវត្ថុដែលធ្វើសវនកម្មដោយសវនករឯករាជ្យរបស់ក្រុមហ៊ុនបោះផ្សាយដោយអគ្គនាយកដ្ឋានពន្ធដារ។ កិច្ចប្រជុំពិភាក្សានេះធ្វើឡើងក្នុងគោលបំណងឆ្លើយតបនឹងតម្រូវការទីផ្សារ និងដើម្បីលើកកម្ពស់ការចូលរួមរបស់វិស័យឯកជនក្នុងវិស័យមូលបត្រដែលជាកត្តាលីករជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម រស់ សីលវ៉ា** រដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ព្រមទាំងមានការចូលរួមពីអគ្គនាយកដ្ឋានពន្ធដារ និងនិយ័តករមូលបត្រកម្ពុជាផងដែរ។

## កិច្ចប្រជុំកម្រិតថ្នាក់ដឹកនាំលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការពិន័យអន្តរការណ៍ចំពោះបទល្មើសនឹងច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម



៤.កាលពីថ្ងៃអង្គារ ១កើត ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី៣ ខែកញ្ញា គ.ស. ២០២៤ នៅបន្ទប់ប្រជុំធំ និយ័តករគណនេយ្យនិងសវនកម្ម **ឯកឧត្តម ម៉ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយ **លោកស្រី នាន បូនី** អគ្គនាយករង និង **លោក លី កុសល** អនុប្រធាននាយកដ្ឋានទទួលបន្ទុករួមនៃនាយកដ្ឋានកិច្ចការគតិយុត្តនិងអនុលោមភាព និងមន្ត្រីជំនាញ នៃ **ន.គ.ស.** បានចូលរួមកិច្ចប្រជុំកម្រិតថ្នាក់ដឹកនាំលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការពិន័យអន្តរការណ៍ចំពោះបទល្មើសនឹងច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម និង"សេចក្តីព្រាងប្រកាសស្តីពីកាតព្វកិច្ចដាក់តម្កល់របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំនិងដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ងី តាយី** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាសមាជិកក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ក្នុងគោលបំណងរាយការណ៍វឌ្ឍនភាព និងឆ្លងយោបល់ ដើម្បីត្រៀមកិច្ចប្រជុំក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ។

## កិច្ចប្រជុំលើកទី៣ របស់អនុគណៈកម្មាធិការគ្រប់គ្រងការប្រឡង នៃគណៈកម្មាធិការគ្រប់គ្រងកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា



៥.កាលពីថ្ងៃពុធ ២កើត ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី៤ ខែកញ្ញា គ.ស. ២០២៤ នៅអគារការិយាល័យ ៣៤៥ **លោកស្រី នាន បូនី** អគ្គនាយករង នៃនិយ័តករគណនេយ្យនិងសវនកម្ម និងជាប្រធានអនុគណៈកម្មាធិការគ្រប់គ្រងការប្រឡង បានដឹកនាំកិច្ចប្រជុំលើកទី៣ របស់អនុគណៈកម្មាធិការគ្រប់គ្រងការប្រឡង នៃគណៈកម្មាធិការគ្រប់គ្រងកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា (គ.ក.គ.ក.) ដោយមានការអញ្ជើញចូលរួមពី លោកអនុប្រធាន សមាជិកអនុគណៈគ្រប់គ្រងការប្រឡង និងលេខាធិការដ្ឋាន។

## កិច្ចប្រជុំដើម្បីពិនិត្យនិងពិភាក្សាលើ "សេចក្តីព្រាងបឋមគោលការណ៍ណែនាំស្តីពីកិច្ចបញ្ជិកាគណនេយ្យនៃសន្និធិ"



៦.កាលពីថ្ងៃពុធ ២ កើត ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៤ ខែកញ្ញា គ.ស. ២០២៤ ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម ម៉ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម **លោកស្រី ពេជ្រ ម៉ានីឡា** អនុប្រធាននាយកដ្ឋានបច្ចេកទេស អមដោយមន្ត្រីជំនាញនៃនាយកដ្ឋានបច្ចេកទេស បានចូលរួមកិច្ចប្រជុំដើម្បីពិនិត្យនិងពិភាក្សាលើ "សេចក្តីព្រាងបឋមគោលការណ៍ណែនាំស្តីពីកិច្ចបញ្ជិកាគណនេយ្យនៃសន្និធិ" និង "សេចក្តីព្រាងបឋមគោលការណ៍ណែនាំស្តីពីឥទ្ធិពលនៃការប្រែប្រួលអត្រាប្តូរប្រាក់រូបិយប័ណ្ណបរទេស" ដែលដឹកនាំដោយអគ្គនាយកដ្ឋានរតនាគារជាតិ ដោយមានការចូលរួមពីតំណាងអគ្គនាយកដ្ឋានរតនាគារជាតិ និយ័តករគណនេយ្យនិងសវនកម្ម និងអគ្គនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមប្រព័ន្ធអនឡាញ។

## សិក្ខាសាលាស្តីពីស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ (IFRS) លេខ ១៨ "ការដាក់បង្ហាញ និងការលាតត្រដាងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ"



៧.កាលពីថ្ងៃសុក្រ ៤កើត ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៦ ខែកញ្ញា គ.ស.២០២៤ ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម ម៉ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម **លោក ហេង សំណាង** ប្រធានការិយាល័យស្តង់ដាគណនេយ្យសាធារណៈ និង **លោក ពេជ សុភាចារ** មន្ត្រីការិយាល័យស្តង់ដាគណនេយ្យឯកជន នៃនាយកដ្ឋានបច្ចេកទេស បានចូលរួមសិក្ខាសាលាស្តីពីស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ (IFRS) លេខ ១៨ "ការដាក់បង្ហាញ និងការលាតត្រដាងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ" ដែលបានសហការរៀបចំឡើងដោយក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិ (IASB) និងក្រុមប្រឹក្សាស្តង់ដាគណនេយ្យម៉ាឡេស៊ី (MASB) នៅទីក្រុងកូឡាឡាំពួរប្រទេសម៉ាឡេស៊ី។ សិក្ខាសាលានេះត្រូវបានរៀបចំឡើងក្នុងគោលបំណងស្វែងយល់កាន់តែច្បាស់អំពីលក្ខខណ្ឌចាំបាច់គន្លឹះនៃស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ (IFRS) លេខ១៨ ដែលនឹងធ្វើឱ្យប្រសើរឡើងនូវរបៀបដែលក្រុមហ៊ុនប្រាស្រ័យទាក់ទង ព័ត៌មាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុជាមួយនឹងការផ្តោតលើព័ត៌មានអំពីលទ្ធផលហិរញ្ញវត្ថុនៅក្នុងរបាយការណ៍ចំណេញឬខាត។ ស្តង់ដា IFRS 18 នឹងជំនួសស្តង់ដាគណនេយ្យអន្តរជាតិ (IAS) លេខ១ "ការដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុ" ហើយចូលជាធរមាន ចាប់ពីថ្ងៃទី ១ ខែមករា គ.ស.២០២៧។

## សិក្ខាសាលាផ្សព្វផ្សាយ "ច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធ ជូនសាស្ត្រាចារ្យនិងនិស្សិត នៃសាកលវិទ្យាល័យស្វាយរៀង



៨.កាលពីថ្ងៃសៅរ៍ ៥កើត ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី៧ ខែកញ្ញា គ.ស. ២០២៤ និយ័តករគណនេយ្យនិងសវនកម្ម នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ បានសហការជាមួយសាកលវិទ្យាល័យស្វាយរៀង រៀបចំសិក្ខាសាលាផ្សព្វផ្សាយ "ច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធ ជូនសាស្ត្រាចារ្យនិងនិស្សិត នៃសាកលវិទ្យាល័យស្វាយរៀង ខេត្តស្វាយរៀង ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ម៉ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយ **លោក លី កុសល** អនុប្រធាននាយកដ្ឋានទទួលបន្ទុករួម នៃនាយកដ្ឋានកិច្ចការគតិយុត្តនិងអនុលោមភាព ព្រមទាំង **ឯកឧត្តមសាស្ត្រាចារ្យ ទុំ សារារុធ** សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យស្វាយរៀងព្រមទាំង **លោកស្រី សារុធ ដាលី** នាយកប្រតិបត្តិ នៃវិទ្យាស្ថានគណនេយ្យករជំនាញនិងសវនករកម្ពុជា លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស ចំនួន៣៥០នាក់។ សិក្ខាសាលានេះត្រូវបានរៀបចំឡើងក្នុងគោលបំណងផ្សព្វផ្សាយនិងបញ្ជ្រាបការយល់ដឹងអំពីច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងគណនេយ្យនិងសវនកម្ម ព្រមទាំងស្តង់ដាបច្ចេកទេសនៅកម្ពុជាដល់សាស្ត្រាចារ្យ និងនិស្សិតដែលកំពុងសិក្សាជំនាញពាក់ព័ន្ធ។

## កិច្ចប្រជុំពិភាក្សាអំពីរបកគំហើញសវនកម្មប្រចាំឆ្នាំ២០២៣ ក្រោមក្របខ័ណ្ឌគម្រោង/កម្មវិធីហិរញ្ញប្បទានពីដៃគូអភិវឌ្ឍ




៩.កាលពីថ្ងៃពុធ ៩កើត ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១១ ខែកញ្ញា គ.ស. ២០២៤ **លោកស្រី នាន បូនី** អគ្គនាយករងតំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ម៉ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយ**លោក យេម ឆៃយ៉ា** អនុប្រធានការិយាល័យគណនេយ្យនិងហិរញ្ញវត្ថុ បានអញ្ជើញចូលរួមកិច្ចប្រជុំពិភាក្សាអំពីរបកគំហើញសវនកម្មប្រចាំឆ្នាំ២០២៣ ក្រោមក្របខ័ណ្ឌគម្រោង/កម្មវិធីហិរញ្ញប្បទានពីដៃគូអភិវឌ្ឍ ដែលដឹកនាំដោយ **ឯកឧត្តម ប៉ែន ធីរុទ្ធ** អនុរដ្ឋលេខាធិការ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## សិក្ខាសាលាស្តីពី "របាយការណ៍ហិរញ្ញវត្ថុរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ"



១០.កាលពីថ្ងៃពុធ ៩កើត ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១១ ខែកញ្ញា គ.ស.២០២៤ ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម ម៉ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម **លោកស្រី ពេជ្រ ម៉ានីឡា** អនុប្រធាននាយកដ្ឋាន

បច្ចេកទេស អមដោយ **លោក ពេជ សុភាចារ** មន្ត្រីនៃនាយកដ្ឋានបច្ចេកទេស បានចូលរួមសិក្ខាសាលាស្តីពី "របាយការណ៍ហិរញ្ញវត្ថុរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ"សហការរៀបចំឡើងនិយ័តករមូលបត្រកម្ពុជានិងក្រុមហ៊ុន អេហ្វអាយអាយ &អ៊ីសូស៊ីអេត នៅអគារអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ក្រោមការដឹកនាំរបស់ **ឯកឧត្តម សៀង ជីវិទ្ធ** អគ្គនាយករង នៃនិយ័តករមូលបត្រកម្ពុជា ក្នុងគោលបំណងបញ្ជ្រាបការយល់ដឹងពាក់ព័ន្ធនឹងកាតព្វកិច្ចក្នុងការបង្ហាញព័ត៌មានសាជីវកម្មដល់បុគ្គលចុះបញ្ជីលក់មូលបត្រ។

## កម្មវិធីប្រគល់វិញ្ញាបនបត្រវគ្គបណ្តុះបណ្តាលស្តីពី "ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូចនិងមធ្យម"



១១.កាលពីថ្ងៃអង្គារ ៨កើត ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី១០ ខែកញ្ញា គ.ស.២០២៤ និយ័តករគណនេយ្យនិងសវនកម្មនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ បានរៀបចំកម្មវិធីប្រគល់វិញ្ញាបនបត្រវគ្គបណ្តុះបណ្តាលស្តីពី "ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូចនិងមធ្យម" នៅអគារ៣៤៥។ វគ្គបណ្តុះបណ្តាលនេះប្រព្រឹត្តទៅក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ម៉ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយ **លោកស្រី នាន បូនី** អគ្គនាយករង និង **លោក លី កុសល** អនុប្រធាននាយកដ្ឋានទទួលបន្ទុករួមនៃនាយកដ្ឋានកិច្ចការគតិយុត្តនិងអនុលោមភាព និង **លោក សាយ សុខខេង** អគ្គនាយកក្រុមហ៊ុនDFC ព្រមទាំងថ្នាក់ដឹកនាំនិងមន្ត្រីនៃ និយ័តករគណនេយ្យនិងសវនកម្ម និងសិក្ខាកាមដែលបានប្រឡងជាប់ស្ពាពរចំនួន១១៦នាក់។

## វគ្គបណ្តុះបណ្តាលស្តីពី "ស្តង់ដាររបាយការណ៍ទាក់ទង នឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូចនិងមធ្យម"




១២.កាលពីថ្ងៃសៅរ៍ ១២កើត ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី១៤ ខែកញ្ញា គ.ស. ២០២៤ និយ័តករគណនេយ្យនិងសវនកម្ម នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី "ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូចនិងមធ្យម"វគ្គទី៨ រយៈពេល៦ថ្ងៃនៅអគារ៣៤៥។ វគ្គបណ្តុះបណ្តាលនេះប្រព្រឹត្តទៅក្រោមអធិបតីភាពរបស់ **លោកស្រី នាន បូនី** អគ្គនាយករង តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ម៉ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយ **លោក លី កុសល** អនុប្រធាននាយកដ្ឋានទទួលបន្ទុករួម នៃនាយកដ្ឋានកិច្ចការគតិយុត្តនិងអនុលោមភាព រួមទាំង **កញ្ញា វីរៈ បូរមី** តំណាងក្រុមហ៊ុនDFC ព្រមទាំងថ្នាក់ដឹកនាំនិងមន្ត្រី នៃនិយ័តករគណនេយ្យនិងសវនកម្ម ដែលមានការចូលរួមពីសិក្ខាកាមចំនួន៦០នាក់។

វគ្គបណ្តុះបណ្តាលបានរៀបចំឡើងនៅក្នុងគោលដៅបញ្ជ្រាបការយល់ដឹង និងសិក្សាលម្អិតលើស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូចនិងមធ្យម ដែលជាមូលដ្ឋានក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ និងសម្រាប់ការចូលរួមអនុវត្តកាតព្វកិច្ចគណនេយ្យនិងសវនកម្មដូចមានចែងក្នុងច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធ។

## ចូលរួមធ្វើបទបង្ហាញស្តីពីកាតព្វកិច្ចគណនេយ្យនិងសវនកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធ និងទស្សនាទានគោលការណ៍ទូទៅគណនេយ្យ ជូនរដ្ឋាករទឹកទាំង៩



១៣.កាលពីថ្ងៃចន្ទ ១៤ កើត ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១៦ ខែកញ្ញា គ.ស.២០២៤ ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម ម៉ី ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម **លោក ម៉ាច់ ដារ៉ា** អនុប្រធានការិយាល័យនីតិកម្ម និងដោះស្រាយវិវាទ **លោក ពេជ សុភាចារ** និង**កញ្ញា ឡាំ ដាណេ** មន្ត្រីនៃន.គ.ស. បានចូលរួមធ្វើបទបង្ហាញស្តីពីកាតព្វកិច្ចគណនេយ្យនិងសវនកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធ និងទស្សនាទានគោលការណ៍ទូទៅគណនេយ្យជូនរដ្ឋាករទឹកទាំង៩ដែលទើបបង្កើតឡើង។ វគ្គបណ្តុះបណ្តាលសហការរៀបចំដោយក្រុមការងារកែទម្រង់ការគ្រប់គ្រងសហគ្រាសសាធារណៈនិងអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមបណ្ឌិត អៀង ស៊ុនលី** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងជាប្រធានក្រុមការងារកែទម្រង់ការគ្រប់គ្រងសហគ្រាសសាធារណៈ និង **ឯកឧត្តម យ៉េត វីណែល** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងជាអគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង **ឯកឧត្តម នេត មុន្នី** ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅខេត្តសៀមរាប។ វគ្គបណ្តុះបណ្តាលនេះត្រូវបានរៀបចំឡើងក្នុងគោលបំណងបញ្ជ្រាបការយល់ដឹងអំពីសញ្ញាណទូទៅនៃសហគ្រាសសាធារណៈ និងពង្រឹងសមត្ថភាពបន្ថែមដល់រដ្ឋាករទឹកក្នុងការគ្រប់គ្រងអាជីវកម្មឱ្យកាន់តែមានប្រសិទ្ធភាព។

## សិក្ខាសាលាត្រៀមលក្ខណៈសម្រាប់ការរៀបចំថវិកា និងទិសដៅការងារឆ្នាំ២០២៥ របស់ អ.ស.ហ.



១៤.កាលពីថ្ងៃអង្គារ ១៥កើត ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១៧ ខែកញ្ញា គ.ស. ២០២៤ **លោកស្រី នាន មុនី** អគ្គនាយករង តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ម៉ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយ **លោក ទឹម សត្យា** អនុប្រធាននាយកដ្ឋានទទួលបន្ទុករួមនៃនាយកដ្ឋានកិច្ចការទូទៅ **លោកស្រី ហា សុគន្ធា** ប្រធានការិយាល័យគណនេយ្យនិងហិរញ្ញវត្ថុ និង **លោក យេម ឆៃយ៉ា** អនុប្រធានការិយាល័យគណនេយ្យនិងហិរញ្ញវត្ថុ បានអញ្ជើញចូលរួមសិក្ខាសាលាត្រៀមលក្ខណៈសម្រាប់ការរៀបចំថវិកានិងទិសដៅការងារឆ្នាំ២០២៥ របស់ អ.ស.ហ. ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ម៉ី វ៉ាន់** រដ្ឋលេខាធិការ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន **អ.ស.ហ.**។

## កិច្ចប្រជុំនិងពិភាក្សាក្រុមការងារលើកកម្ពស់ការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ



១៥.កាលពីថ្ងៃអង្គារ ១៥កើត ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១៧ ខែកញ្ញា គ.ស.២០២៤ **លោកស្រី នាន មុនី** អគ្គនាយករង តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ម៉ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយមន្រ្តីជំនាញជាសមាជិកក្រុមការងារបានចូលរួមកិច្ចប្រជុំនិងពិភាក្សាក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ម៉ី វ៉ាន់** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនិងជាអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន អ.ស.ហ. និងជាប្រធានក្រុមការងារនៃក្រុមការងារទាំងពីរដែលមានរបៀបវារៈដូចខាងក្រោម៖ ១.កិច្ចប្រជុំដំបូងរបស់ក្រុមការងារលើកកម្ពស់ការអភិវឌ្ឍន៍បច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ, ២.កិច្ចប្រជុំលើកទី២របស់ក្រុមការងាររៀបចំសេចក្តីព្រាងផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍បច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ,៣.កិច្ចពិភាក្សាវឌ្ឍនភាពការងារអំពី "ការចុះអនុស្សរណៈនៃការយោគយល់គ្នារវាងអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ និងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍"។

## កម្មវិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាស្តីពី "កិច្ចសហប្រតិបត្តិការលើការលើកកម្ពស់ការយល់ដឹង និងជំរុញការចូលរួមអភិវឌ្ឍន៍វិស័យមូលបត្រនៅព្រះរាជាណាចក្រកម្ពុជា"



© រក្សាសិទ្ធិដោយ និយ័តករគណនេយ្យនិងសវនកម្ម

១៦.កាលពីថ្ងៃអង្គារ ១៥កើត ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី១៧ ខែកញ្ញា គ.ស.២០២៤ ដោយបានទទួលការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម ម៉ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម **លោក ណុប សម្បត្តិ** អនុប្រធាននាយកដ្ឋាន អមដោយ លោក **សេង ម៉េងហ័រ** មន្ត្រីជំនាញ នៃនាយកដ្ឋានគ្រប់គ្រងវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម បានចូលរួមកម្មវិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាស្តីពី "កិច្ចសហប្រតិបត្តិការលើការលើកកម្ពស់ការយល់ដឹងនិងជំរុញការចូលរួមអភិវឌ្ឍវិស័យមូលបត្រនៅព្រះរាជាណាចក្រកម្ពុជា" រវាងនិយ័តករមូលបត្រកម្ពុជា និងសមាគមសហព័ន្ធអ្នកវិនិយោគកម្ពុជា និងសិក្ខាសាលាផ្សព្វផ្សាយស្តីពី "កាលានុវត្តភាពតាមរយៈទីផ្សារមូលបត្រនៅកម្ពុជា" ។

## កិច្ចប្រជុំពិនិត្យ និងពិភាក្សាលើ "វឌ្ឍនភាពការងារលើការរៀបចំសេចក្តីព្រាងប្រកាសស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីកិច្ចបញ្ជិកាគណនេយ្យនៃប្រតិបត្តិការថវិកាក្នុងគណនេយ្យថវិកា"




១៧.កាលពីថ្ងៃពុធ ១ រោច ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១៨ ខែកញ្ញា គ.ស. ២០២៤ ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម ម៉ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម **លោកស្រី ពេជ្រ ម៉ានីឡា** អនុប្រធាននាយកដ្ឋានបច្ចេកទេស អមដោយ**លោក ហេង សំណាង** ប្រធានការិយាល័យស្តង់ដាគណនេយ្យសាធារណៈ បានចូលរួមកិច្ចប្រជុំដើម្បីពិនិត្យ និងពិភាក្សាលើ "វឌ្ឍនភាពការងារលើការរៀបចំសេចក្តីព្រាងប្រកាសស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីកិច្ចបញ្ជិកាគណនេយ្យនៃប្រតិបត្តិការថវិកាក្នុងគណនេយ្យថវិកា" ដែលដឹកនាំដោយ **ឯកឧត្តម ជូ គឹមឡេង** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងមានការចូលរួមពីតំណាងឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាន កញ្ញា ដែលជាសមាជិកក្រុមការងារបច្ចេកទេសសម្រាប់រៀបចំ" សេចក្តីព្រាងប្រកាសស្តីពីការដាក់ឱ្យអនុវត្តគណនេយ្យថវិកា" តាមប្រព័ន្ធអនឡាញ។

## កម្មវិធីចុះអនុស្សរណៈនៃការយោគយល់គ្នារវាងនិយ័តករមូលបត្រកម្ពុជា និងគណៈកម្មការរដ្ឋាភិបាលឌីជីថលស្តីពី "កិច្ចសហប្រតិបត្តិការដាក់ឱ្យប្រើប្រាស់ថ្នាលផ្ទៀងផ្ទាត់ឯកសារ verify.gov.kh និងការបណ្តុះបណ្តាលជំនាញឌីជីថលជូនមន្ត្រី នៃ ន.ម.ក."



១៨.កាលពីថ្ងៃសុក្រ ៣រោច ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២០ ខែកញ្ញា គ.ស. ២០២៤ **លោកស្រី នាន មុនី** អគ្គនាយករង តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ម៉ី ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយ **លោក ទឹម សត្យា** អនុប្រធាននាយកដ្ឋានកិច្ចការទូទៅ និង **លោក ជីវ ហ៊** ប្រធានការិយាល័យគ្រប់គ្រងព័ត៌មានវិទ្យា បានអញ្ជើញចូលរួមកម្មវិធីចុះអនុស្សរណៈនៃការយោគយល់គ្នារវាងនិយ័តករមូលបត្រកម្ពុជា និងគណៈកម្មការរដ្ឋាភិបាលឌីជីថលស្តីពី "កិច្ចសហប្រតិបត្តិការដាក់ឱ្យប្រើថ្នាលផ្ទៀងផ្ទាត់ឯកសារ verify.gov.kh និងការបណ្តុះបណ្តាលជំនាញឌីជីថលជូនមន្ត្រី នៃ ន.ម.ក." ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ស៊ូ សុជាតិ** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃនិយ័តករមូលបត្រកម្ពុជា។

## កិច្ចប្រជុំពិគ្រោះយោបល់ជាមួយក្រុមបេសកកម្មមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ក្នុងក្របខ័ណ្ឌទស្សនកិច្ចពិគ្រោះយោបល់ប្រចាំឆ្នាំ២០២៤



១៩.កាលពីថ្ងៃព្រហស្បតិ៍ ២ រោច ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី១៩ ខែកញ្ញា គ.ស. ២០២៤ **លោកស្រី នាន មុនី** អគ្គនាយករង តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ម៉ី ថារិន** អគ្គនាយកនៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយ **លោក លឹម ចាន់រតនៈ** មន្ត្រីជំនាញ និងជាសមាជិកក្រុមការងារស្ថិរភាពហិរញ្ញវត្ថុនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) បានចូលរួមកិច្ចប្រជុំពិគ្រោះយោបល់ជាមួយក្រុមបេសកកម្មមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ក្នុងក្របខ័ណ្ឌទស្សនកិច្ចពិគ្រោះយោបល់ប្រចាំគ.ស. ២០២៤ (2024 Article IV Consultation) ជាមួយស្ថាប័នរាជរដ្ឋាភិបាល អង្គភាពពាក់ព័ន្ធនិងវិស័យឯកជន ដើម្បីពិភាក្សាលើការវិវត្តន៍ ម៉ាក្រូសេដ្ឋកិច្ច ទស្សនវិស័យ និងគោលនយោបាយ។ កិច្ចប្រជុំពិគ្រោះយោបល់នេះ ដឹកនាំដោយ **លោកបណ្ឌិត សោម ផៃ** អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋាន អ.ស.ហ. និងមានការអញ្ជើញចូលរួមដោយ ថ្នាក់ដឹកនាំ និងមន្ត្រីនៃនិយ័តករទាំងអស់ក្រោមឱវាទ អ.ស.ហ. ដោយផ្តោតសំខាន់ទៅលើអន្តរតំណរនៃអនុវិស័យនីមួយៗទៅលើវិស័យអចលនទ្រព្យ។

# សន្និសីទអ្នកកំណត់ស្តង់ដាពិភពលោកលើកទី២៣ (23rd World Standard Setters Conference) នៅទីក្រុងឡុងដ៍ ចក្រភពអង់គ្លេស




២០.កាលពីថ្ងៃអង្គារ ៧រោច ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី២៤ ខែកញ្ញា គ.ស. ២០២៤ **ឯកឧត្តម ម៉ី ថារិន** អគ្គនាយកនៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយ **លោក លោកស្រី** អគ្គនាយករង ថ្នាក់ដឹកនាំ មន្ត្រីជំនាញ នៃនិយ័តករគណនេយ្យនិងសវនកម្ម និងលោក **ខេស៊ី ចាណោត** ទីប្រឹក្សានិយ័តករគណនេយ្យនិងសវនកម្ម បានចូលរួមសន្និសីទអ្នកកំណត់ស្តង់ដាពិភពលោកលើកទី២៣ (23rd World Standard Setters Conference) នៅទីក្រុងឡុងដ៏ចក្រភពអង់គ្លេស រៀបចំឡើងដោយមូលនិធិស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ (International Financial Reporting Standards Foundation) ដោយមានអ្នកចូលរួមប្រហែល ១៤០នាក់ មកពីតំណាងប្រទេសចំនួន៧០។ សន្និសីទអ្នកកំណត់ស្តង់ដាពិភពលោកឆ្នាំនេះត្រូវបានរៀបចំឡើងក្នុងគោលបំណងបង្ហាញអំពីបច្ចុប្បន្នភាពនៃសកម្មភាពរបស់មូលនិធិស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ,ក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិ(IASB) និងក្រុមប្រឹក្សាស្តង់ដាចីរភាពអន្តរជាតិ (ISSB) ដូចជាវិសោធនកម្មទៅលើស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ (International Financial Reporting Standards - IFRS) មួយចំនួន,ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិសម្រាប់សហគ្រាសធុនតូចនិងមធ្យម(International Financial Reporting Standards for SMEs) កំណែប្រែលើកទី៣, និងការផ្សព្វផ្សាយការអនុវត្តស្តង់ដា IFRS S1 លក្ខខណ្ឌចាំបាច់ទូទៅសម្រាប់ការលាតត្រដាងព័ត៌មានហិរញ្ញវត្ថុទាក់ទងនឹងចីរភាព (General Requirements for Disclosure of Sustainability-related Financial Information) និង IFRS S2 ការលាតត្រដាងព័ត៌មានទាក់ទងនឹងអាកាសធាតុ (Climate-related Disclosures)។ លើសពីនេះទៀត ព្រឹត្តិការណ៍នេះក៏បានផ្តល់ឱកាសដល់ស្ថាប័នកំណត់ស្តង់ដានៅក្នុងប្រទេសនីមួយៗ ចូលរួមបញ្ចេញមតិយោបល់អំពីបញ្ហាប្រឈមក្នុងការអនុវត្តនៅប្រទេសរបស់

ខ្លួនទៅកាន់មូលនិធិស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ  ក៏ដូចជាចូលរួមក្នុងវេទិកាផ្សេងៗដើម្បីទទួលបានព័ត៌មានថ្មីៗស្តីពីវឌ្ឍនភាពស្តង់ដាអន្តរជាតិ ក៏ដូចជាធ្វើការចូលរួមកសាងនូវបណ្តាញទំនាក់ទំនងផងដែរ។

រៀបចំដោយ÷**លោក ឡាយ វិចិត្រ**

សម្របសម្រួលអត្ថបទ÷**កញ្ញា សុខ ណារី**

© រក្សាសិទ្ធិដោយ និយ័តករគណនេយ្យនិងសវនកម្ម